ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ទីភ្នាក់ងារជ្រើសរើសឯកជនដែលបានទទួលការអនុញ្ញាតឱ្យធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសសិង្ហបុរី

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនសាធារណជនទាំងអស់ ឱ្យបានជ្រាបថា ទីភ្នាក់ងារជ្រើសរើសឯកជនដែលមានសិទ្ធិធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសសិង្ហបុរី ចំនួន ៤ ដែលមានសកម្មភាព ដូចមានឈ្មោះខាងក្រោម៖

| ល.រ<br>No. | លេខបញ្ជី<br>Registration Number | ឈ្មោះក្រុមហ៊ុន<br>Company Name | ឆ្នាំចុះបញ្ជី<br>Year of Registration | អាសយដ្ឋាន<br>Address | លេខទូរសព្ទ<br>Telephone |
|---|---|---|---|---|---|
| 1 | 011 | **អ៊ឹង រិទ្ធី គ្រុប ឯ.ក**<br>UNG RITHY GROUP CO., LTD. | 2006 | ផ្ទះលេខ៤៣A ផ្លូវលេខ២៧១ ភូមិ១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ<br>No.43A, St.271, Phum1, Sangkat Phsar Deum Thkov, Khan Cham Kar Mon, Phnom Penh. | 071 686 9966<br>015 365 777<br>012 365 777 |
| 2 | 040 | **57 ហ្គោល មេនផៅវ័រ**<br>57 GOAL MANPOWER CO., LTD. | 2014 | ផ្ទះលេខ១៧៤ ផ្លូវលេខ២១BTZ ភូមិសន្សំកុសល១ សង្កាត់បឹងទំពុន១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ<br>No.174, St.21BTZ, Phum Sansomkosal1, Sangkat Boeung Tumpun1, Khan Meanchey, Phnom Penh. | 081 666 653<br>071 666 9596 |
| 3 | 075 | **មាស សុវណ្ណ មាលិកេ មេនផៅវ័រ ឯ.ក**<br>MEAS SOVANN MEALEAKE MANPOWER CO., LTD. | 2017 | ផ្ទះលេខ៤៦៨ ផ្លូវលេខ១០១១ ភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>No.468, St.1011, Phum Phnom Penh Thmey, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh. | 092 231 111<br>097 888 3888 |
| 4 | 101 | **ហ្គូដ យ៉ប មេន ផៅវ័រ អ៊ិនធើណេសិនណាល ឯ.ក**<br>GOOD JOB MAN POWER INTERNATIONAL CO., LTD. | 2018 | ផ្ទះលេខ១១០A ក្រុម៧ ភូមិឫស្សី១ សង្កាត់ស្ទឹងមានជ័យ៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ<br>No.110A, Group7, Phum Russei1, Sangkat Stueng Meanchey3, Khan Meanchey, Phnom Penh. | 012 742 100<br>015 742 100<br>061 448 880 |

បងប្អូនដែលមានបំណងស្វែងរកការងារធ្វើនៅប្រទេសសិង្ហបុរី អាចពិនិត្យមើលបញ្ជីឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជន ដែលមាននៅក្នុងគេហទំព័ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ www.mlvt.gov.kh ឬអាចជ្រើសរើសទីភ្នាក់ងារជ្រើសរើសឯកជន និងចុះឈ្មោះស្វែងរកការងារធ្វើនៅប្រទេសសិង្ហបុរី ដោយផ្ទាល់តាមកម្មវិធីទូរសព្ទដៃ "MLVT Services" ឬតាមទូបញ្ជរសេវាសាធារណៈចល័តរបស់ក្រសួងការងារ និងបណ្តុះបណ្តាល



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

វិជ្ជាជីវៈ ដែលមាននៅក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួង ស្ថាប័នផ្សេងៗ ផ្សារទំនើប ហាងកាហ្វេ ម៉ាតធំៗ និងទីប្រជុំជនសំខាន់ៗ នៅក្នុងរាជធានីភ្នំពេញ។ លោកអ្នកក៏អាចស្វែងរកបញ្ជីឈ្មោះ និងឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជន និងអាចតាមដានដំណើរការឯកសារចាប់ពីការចុះឈ្មោះស្វែងរកការងារធ្វើនៅប្រទេសសិង្ហបុរី រហូតដល់ធ្វើមាតុភូមិនិវត្តន៍មកប្រទេសកំណើតវិញ ដោយខ្លួនឯងផ្ទាល់តាមរយៈតំណភ្ជាប់ https://tracking.ocwc.co/។

រាល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងឡាយណាដែលមិនមានឈ្មោះក្នុងបញ្ជីខាងលើនេះ គឺចាត់ទុកថាជាទីភ្នាក់ងារជ្រើសរើសឯកជនខុសច្បាប់ ដូច្នេះសូមសាធារណជនរាយការណ៍ជាបន្ទាន់មកក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈតាមរយៈ Hotline លេខ១២៨៦/១២៩៧ លេខទូរសព្ទ ០៨៩ ៩៥៧ ៧៨៩ ឬក្រុមតេឡេក្រាម "**សម្រាប់ ពលករទេសន្តរប្រវេសន៍**" តាមតំណភ្ជាប់ https://t.me/KhmerMigrantWorker ឬទំនាក់ទំនងមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈទាំង២៥ រាជធានី ខេត្ត នៅរៀងរាល់ម៉ោងធ្វើការ។

ដើម្បីជៀសវាងការផ្សព្វផ្សាយព័ត៌មានខុស ដែលអាចនាំឱ្យប្រជាពលរដ្ឋរងគ្រោះ ដោយសារការផ្សព្វផ្សាយពាណិជ្ជកម្មពាក់ព័ន្ធនឹងការជ្រើសរើស ឬផ្ដល់សេវារកការងារឱ្យធ្វើនៅបរទេសដល់ពលករខ្មែរនៅតាមបណ្ដាសារព័ត៌មានណាមួយ ជាពិសេសតាមបណ្ដាស្ថានីយ៍វិទ្យុត្រូវមានលិខិតអនុញ្ញាតចេញដោយអគ្គនាយកដ្ឋានការងារនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈជាមុន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន អង្គភាពពាក់ព័ន្ធ បណ្ដាសារព័ត៌មានទាំងអស់ជ្រាបជាព័ត៌មាន និងសហការអនុវត្ត។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៥

"សម្រាប់ពលករទេសន្តរប្រវេសន៍"

"MLVT Services"